# បុរាណវត្ថុវិទ្យា សហគមន៍ និងការគ្រប់គ្រងបេតិកភណ្ឌ : ករណីការងារអភិរក្សនៅឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម

Archaeology, Community, and Heritage Management: The Case of Conservation Work in Baray Commune, Srei Santhor District, Kampong Cham Province

*ដោយ* : **បណ្ឌិត ផុន កសិកា**

*ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

## ១. សេចក្តីផ្តើម

*ឃុំបារាយណ៍ ដែលស្ថិតនៅស្រុកស្រីសន្ធរ ខេត្តកំពង់ចាម គឺជាឃុំមួយស្ថិតក្នុងតំបន់ទំនាបកណ្តាល នៅចន្លោះទន្លេធំ២គឺទន្លេមេគង្គលើនិងទន្លេតូច មានព្រៃក បឹងធម្មជាតិជាច្រើនទៀត។ កត្តាភូមិសាស្ត្រឃុំបារាយណ៍មានអំណោយផលដល់ការធ្វើកសិកម្មស្រូវ និងការចិញ្ចឹមសត្វពាហនៈ គោ និងក្របី ជាដើម។ ឃុំបារាយណ៍បន្សល់ទុកនូវស្ថានីយបុរាណជាច្រើន។ ប្រាសាទព្រះធាតុបារាយណ៍គឺជាប្រាសាទមួយកសាងក្នុងសតវត្សរ៍ទី១១ ហើយដែលអ្នកស្រុកមានជំនឿថានៅសម័យកណ្តាលស្តេចកនបានមកតាំងទីលំនៅនៅប្រាសាទព្រះធាតុបារាយណ៍នេះ។*

*ចាប់តាំងពីឆ្នាំ២០១៩ មក ការសិក្សាស្រាវជ្រាវបុរាណវត្ថុវិទ្យាត្រូវបានអនុវត្តនៅឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដោយសាកលវិទ្យាល័យហ្វ្លីនឌ័រ* (Flinders University) *ប្រទេសអូស្ត្រាលី ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រាជបណ្ឌិត្យសភាកម្ពុជា មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកំពង់ចាម។ ការសិក្សាស្រាវជ្រាវនេះបានរកឃើញស្ថានីយបុរាណ ព្រមទាំងទេសភាពវប្បធម៌ដ៏សម្បូរបែប ដែលក្នុងនោះមានប្រាសាទ គ្រឹះប្រាសាទ ត្រពាំង និងប្រព័ន្ធធារាសាស្ត្រ ដែលអ្នកស្រុកហៅថាទំនប់ និង មេទឹក។ ការសិក្សាស្រាវជ្រាវមានការសហការពីអាជ្ញាធរដែនដីឃុំបារាយណ៍ ព្រមទាំងសហគមន៍ក្នុងឃុំបារាយណ៍ ដើម្បីសហការគ្នាយ៉ាងជិតស្និទ្ធដើម្បីឈានទៅអភិរក្សស្ថានីយបុរាណក្នុងឃុំបារាយណ៍។*

*ការសិក្សាស្រាវជ្រាវមានដូចជាការធ្វើកំណាយ ការស្រាវចុះបញ្ជីនិងធ្វើផែនទីស្ថានីយបុរាណដែលរកឃើញនៅឃុំបារាយណ៍។*

ទិន្នន័យដែលទទួលបានពីការសិក្សាស្រាវជ្រាវនេះត្រូវបានយកទៅប្រើសម្រាប់យន្តការកំណត់ដែនការពារសក្ដានុពលវប្បធម៌នៃស្ថានីយបុរាណ និងឈានទៅចុះបញ្ជីស្ថានីយក្នុងបញ្ជីបេតិកភណ្ឌជាតិរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ក្រៅពីលទ្ធផលទាំងនេះ ការសិក្សាស្រាវជ្រាវក៏បានបង្ហាញអំពីតួនាទីសហគមន៍និងស្ថាប័នជាច្រើនក្នុងការអភិវឌ្ឍន៍ទាំងការស្រាវជ្រាវ និងកិច្ចអភិរក្សរយៈពេលវែង។ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងឃុំបាពយណ៌ក្នុងការផ្ដល់ពត៌មានអំពីប្រវត្តិសាស្ត្រក្នុងតំបន់ និងការចូលរួមអភិរក្សស្ថានីយបុរាណ ទួលបុរាណ គឺជាចំណុចសំខាន់ដែលអ្នកស្រុកអាចទទួលផលត្រឡប់ពីមរតកដែលពួកគាត់បានចូលរួមថែរក្សា។

អត្ថបទនេះបង្ហាញពីការរកឃើញបុរាណវិទ្យា និងដំណើរការគ្រប់គ្រងបេតិកភណ្ឌដោយសហគមន៍ ដែលធ្វើឲ្យការស្រាវជ្រាវអាចទទួលបានជោគជ័យ។ នេះបញ្ជាក់ថា ឃុំបាពយណ៌ គឺជាគំរូនៃការអភិរក្សបេតិកភណ្ឌវប្បធម៌រួមគ្នា នៅប្រទេសកម្ពុជា ដែលអ្នកជំនាញបុរាណវិទ្យាមកស្ថាប័នជាតិនិងស្ថាប័នអន្តរជាតិ ព្រមទាំងសហគមន៍ក៏បានចូលរួមយ៉ាងសកម្មសម្រាប់ជោគជ័យនេះ។



ផែនទីឃុំបាពយណ៌ (ផលិតដោយៈ លោក ឡេង សត្យា)

## ២. បរិបទបុរាណវត្ថុវិទ្យា

ឃុំបាពយណ៌មានសម្បត្តិវប្បធម៌ ដែលជាតឹកតាងនៃបរិបទបុរាណវត្ថុវិទ្យា មានប្រាសាទទួលបុរាណ ប្រព័ន្ធជាពស្រ្ត (មានបាពយណ៌ មេទឹកឬចន្ទក់) និងវត្ថុបុរាណផ្សេងៗ។

### ២.១. ប្រាសាទព្រះធាតុបារយណ៍

ប្រាសាទព្រះធាតុបាពយណ៌គឺជាប្រាសាទបុរាណមួយចាត់ទុកថាជាសម្បត្តិបេតិកភណ្ឌជាតិ ត្រូវបានកសាងនៅក្នុងទឹកដីភូមិស្បាអំពិល ឃុំបាពយណ៌ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ទោះបីប្រាសាទនេះមានរូបរាងតូច មិនធំដូចប្រាសាទនៅតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជាក្ដី ប៉ុន្តែប្រាសាទនេះមានគ្រឿង

បង្គំប្រាសាទមួយចំនួនដែលអាចអ្នកសិក្សាស្រាវជ្រាវអាចកំណត់អាយុកាលប្រាសាទ និង កំណត់រចនាបថរបស់ប្រាសាទបាន។

ប្រាសាទព្រះធាតុបារាយណ៍ជាប្រាសាទដែលត្រូវបានកែបន្ថែមនៅសម័យក្រោយៗមកទៀត ដោយមានការលាបកំបោរបាយអលើតួប្រាសាទ ព្រមទាំងកសាងសំណង់ទីធ្លានៅមុខប្រាសាទ។ ក្រៅពីនោះ ប្រាសាទនេះមិនត្រូវបានសាងសង់ដាច់តែឯងនោះទេ គឺមានគូទឹកបារាយណ៍ដែលជារចនាសម្ព័ន្ធបុរាណវត្ថុនៃប្រាសាទនេះ។



រូបលេខ១: ប្រាសាទព្រះធាតុបារាយណ៍ និងគ្រឿងបង្គំប្រាសាទដាក់នៅផ្នែកខាងកើតនៃតួប្រាសាទ



រូបលេខ២: តួប្រាសាទព្រះធាតុបារាយណ៍

## ២.២. ទួលបុរាណ

នៅឃុំបារាយណ៍ ក្រៅពីប្រាសាទព្រះធាតុបារាយណ៍ នៅមានទួលបុរាណជាច្រើនទៀត ដែលទួលខ្លះជាប្រភេទទួលគ្រឹះប្រាសាទ ជាទួលមនុស្សរស់នៅ ទួលខ្លះអាចជាប្រភេទទួលឡកុលាលភាជន៍ ឬ ជាទួលផ្សេងៗទៀត។



រូបលេខ៣: ទួលតាមោគជាប្រភេទទួលមនុស្សរស់នៅ



រូបលេខ៤: ទួលដើង ស្ថិតក្នុងភូមិបន្ទាយ ជាប្រភេ ទួលប្រាសាទ

## ២.៣. ប្រព័ន្ធធារាសាស្ត្រ

ឃុំបារាយណ៍មានប្រព័ន្ធធារាសាស្ត្រគួរឱ្យកត់សម្គាល់ពីរប្រភេទ គឺបារាយណ៍ និង មេទឹក ដែលអ្នកស្រុកខ្លះហៅចន្ទក់ ឬ ទំនប់មេទឹក។

## ២.៣.១- បារាយណ៍

ពាក្យ "បារាយណ៍" មានន័យជាប់ទាក់ទងយ៉ាងជ្រាលជ្រៅនឹងបេតិកភណ្ឌខ្មែរ ដែលយើងឃើញមានបារាយណ៍ធំៗក្នុងតំបន់អង្គរ ខេត្តសៀមរាប។ ទោះបីឃុំបារាយណ៍មិនមានអាងទឹកធំដូចអង្គរ ក៏ទេសភាពវប្បធម៌នៅទីនេះបង្ហាញពីការគ្រប់គ្រងទឹក និងការរស់នៅរបស់មនុស្ស។

នៅឃុំបារាយណ៍ គេសង់បារាយណ៍ធំមួយដែលអ្នកស្រុកហៅឈ្មោះថា «ស្រែបឹង» មានបណ្ដោយប្រវែង៧៥០ម៉ែត្រ (អ័ក្សកើតលិច) និងទទឹង៤៥០ម៉ែត្រ (អ័ក្សជើងត្បូង)។




រូបលេខ៥ : ប្រាសាទព្រះធាតុបារាយណ៍ និង បារាយណ៍ ដែលអ្នកស្រុកហៅថា «ស្រែបឹង»

នៅចន្លោះពីប្រាសាទទៅបារាយណ៍ «ស្រែបឹង» មានរចនាសម្ព័ន្ធបុរាណវត្ថុអចល័តមួយទៀត ដែលអ្នកស្រុកហៅថា «ទន្លេអុំ» ដោយអ្នកស្រុកមានជំនឿថា នៅសម័យបុរាណចាស់ៗតែងតែមកប្រណាំទូកនៅក្នុងទន្លេអុំនេះ[1]។ នេះគឺជាបារាយណ៍តូចមួយមានបណ្ដោយប្រវែង៣២០ម៉ែត្រ និងទទឹងប្រវែង១០០ម៉ែត្រ។ ទន្លេអុំមាននៅរក្សារូបរាងខ្នងបារាយណ៍ខាងជើង ចំណែកនៅទិសផ្សេងៗទៀត ខ្នងបារាយណ៍ត្រូវបានអ្នកស្រុកឈូសទម្លាយដើម្បីពង្រីកដីធ្វើស្រែ។



រូបលេខ៦ : បារាយណ៍ អ្នកស្រុកហៅថា «ទន្លេអុំ»

## ២.៣.២- មេទឹក

នៅមានទំនប់មេទឹកមួយចំនួនទៀតក្នុងឃុំបារាយណ៍។ អ្នកស្រុកច្រើនហៅទំនប់មេទឹក ឬអ្នកខ្លះក៏ថា ទំនប់វង់កុង ដោយសារទំនប់ប្រភេទនេះរាងកោងដូចចំណិតព្រះចន្ទ

[1] សម្ភាសលោក លឹម ព្រែក ឆ្មាំប្រាសាទព្រះធាតុបារាយណ៍ រស់នៅក្នុងភូមិស្វាអំពិល ឃុំបារាយណ៍ នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៣។

មិនត្រង់ៗ ដូចទំនប់ផ្សេងៗទេ។ ឃុំបាពយណ៍ មានភូមិចំនួន៤ : ភូមិស្បាអំពិល ភូមិបន្ទាយ ភូមិស្បាបឹងវែង និង ភូមិកំផ្លាក់ ដែលភូមិទាំងនោះមានកស្តុតាងស្ថានីយបុរាណពិសេសមេទឹក។

នៅក្នុងភូមិស្បាអំពិលមានមេទឹក ដែលនៅតំបន់នេះគេហៅថាទំនប់សម្រាប់ទប់ទឹកផ្គត់ផ្គង់ដល់ប្រជាពលរដ្ឋមាន៤ គឺបឹងកក់ ដែលជាប្រភពទឹកធំជាងគេ បឹងនន់ស បឹងរាំង តូច បឹងឫស្សី។



រូបលេខ៧ : មេទឹកបឹងកក់ (រូបភាពពីDrone)



រូបលេខ៨ : មេទឹកបឹងឫស្សី (រូបភាពពីGoogle Earth)



រូបលេខ៩ : មេទឹកបឹងរាំង (រូបភាពពីGoogle Earth)



រូបលេខ១០ : មេទឹកនន់ស (ប្រភព : Google Earth)

ក្នុងភូមិស្បាបឹងវែង មេទឹកចន្ទក់ចាស់ ទំនប់ថ្មីមាននិយាមការ មានទួលបុរាណ ជាប្រភេទទួលមនុស្សរស់នៅព័ទ្ធជុំវិញ ដូចជាទួលឡោក ទួលកាន់ស្នេហ៍ ទួលតាពេង ទួលកណ្តាល ទួលថ្មឹង និងទួលពោធិ៍។



រូបលេខ១១ : រូបភាពពីលើអាកាសនៃមេទឹកទំនប់ថ្មី



រូបលេខ១២ : មេទឹកចន្ទក់ចាស់ (រូបភាពពីDrone)

[2] សម្ភាសលោក គង់ សុមុនី ជំទប់ទី១ ឃុំបាពយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

ក្នុងភូមិកំផ្លាក់មានមេទឹកបាយដេ មាន សណ្ឋានស្រដៀងនឹងចន្ទក់ចាស់ និងបឹងវាម។



រូបលេខ១៣ : មេទឹកបាយដេ (រូបភាពពីDrone)



រូបលេខ១៤ : ទិដ្ឋភាពបឹងវាមមើលពីលើអាកាស តាមរយៈរូបថតដ្រូន

ក្នុងភូមិបន្ទាយមានចន្ទក់លិចនៅមាន ខ្នងទំនប់ច្បាស់។




រូបលេខ១៥ : មេទឹកលិចស្ថិតក្នុងភូមិបន្ទាយ

## ២.៤. វត្ថុសិល្បៈផ្សេងៗ

នៅឃុំបាពយណ៍មានកស្តុតាងផ្សេងៗ ទៀត ដូចជាឧបករណ៍ថ្មរំលីង ក្នុងសម័យបុរេប្រវត្តិសាស្ត្រ។



រូបលេខ១៦ : ឧបករណ៍ថ្ម

កស្តុតាងបុរាណវត្ថុមួយចំនួនទៀត មានបំណែកកុលាលភាជន៍ផុយ និងបំណែកកុណ្ឌីដែលប្រភេទកុលាលភាជន៍ផុយដែរ មានដូចជាចំពួយកុណ្ឌី ខ្លួន និងបាត មាន អាយុកាលក្នុងសម័យមុនអង្គរ។



រូបលេខ១៧ : បំណែកកុលាលភាជន៍ និងកុណ្ឌី មានអាយុកាលក្នុងសម័យមុនអង្គរ

នៅមានប្រភេទកុលាលភាជន៍ផ្សេងៗទៀត ដូចជា កុលាលភាជន៍មានប្រភពមកពីតំបន់អង្គរភ្នំគូលេន, កុលាលភាជន៍ទ័ពជ័យ, កុលាលភាជន៍បុរីរម្យ, កុលាលភាជន៍ជើងឯក, កុលាលភាជន៍ចិន និងក្បឿងជាច្រើនទៀត។ ទិន្នន័យនេះក៏អាចបង្ហាញថា ទីតាំងប្រាសាទព្រះធាតុបាពយណ៍ក៏អាចជាទីតាំងផលិតកុលាលភាជន៍នៅសម័យកាលណាមួយដែរ។

ក្រៅពីប្រភេទវត្ថុបុរាណខាងលើ នៅមានបំណែកដុំឥដ្ឋជាច្រើនដែលរកឃើញនៅតាមស្ថានីយ។ ឥដ្ឋទាំងនោះអាចជាប្រភេទឥដ្ឋសម្រាប់សង់ប្រាសាទ, ឥដ្ឋសម្រាប់សង់ឡ ឬឥដ្ឋសម្រាប់សង់សំណង់គោរពបូជាផ្សេងៗទៀត នៅតាមសម័យកាលខុសៗគ្នា។



*រូបលេខ១៨ : បំណែកកុលាលភាជន៍ផ្សេងៗ*



*រូបលេខ១៩ : បំណែកដុំឥដ្ឋ*

## ៣. ការសិក្សាស្រាវជ្រាវធ្វើកំណាយ (២០១៩–២០២៥)

សាកលវិទ្យាល័យហ្វីនឌ័រប្រទេសអូស្ត្រាលីជាអ្នកផ្តួចផ្តើមគំនិតស្រាវជ្រាវ និងសហការជាមួយស្ថាប័នជាតិកម្ពុជាដូចជា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រាជបណ្ឌិត្យសភាកម្ពុជា មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកំពង់ចាម រួមជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋានផងចាប់ផ្តើមចុះស្រាវជ្រាវនិងធ្វើកំណាយនៅឃុំបាពយណ៍ ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៥។



*រូបលេខ២០ : សកម្មភាពកំណាយ នៅឆ្នាំ២០១៩*



*រូបលេខ២១ : សកម្មភាពកំណាយនិងព្រះសង្ឃ និមន្តមកទស្សនារណ្តៅកំណាយ នៅឆ្នាំ២០២៣*

## ៤. សហគមន៍ និងការគ្រប់គ្រងបេតិកភណ្ឌ

***-សហគមន៍មូលដ្ឋាន : ការចូលរួមសហការ និងការថែរក្សា***

*ដោយសារមានជំនឿពីប្រជាពលរដ្ឋក្នុងមូលដ្ឋានចំពោះប្រាសាទព្រះធាតុបាពយណ៌ ពួកគាត់សង់ដំបូលប្រក់ពីស័ង្កសីប្រក់ការពារទឹកភ្លៀងស្រក់ចូលក្នុងប្រាសាទ ក៏ប៉ុន្តែដំបូលនោះចាស់ទ្រុឌទ្រោមខ្លាំង ខូច បាក់ធ្លុះធ្លាយ ធ្វើឲ្យទឹកភ្លៀងហូរចូលក្នុងប្រាសាទ។*

*នៅឆ្នាំ២០២០ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយមានជំនួយថវិកាពីគម្រោងដៃគូមានឈ្មោះថា «គម្រោងស្រាវជ្រាវរាជធានីសម័យកណ្តាល និង បុរាណដ្ឋានជុំវិញ» ដែលដឹកនាំដោយលោកបណ្ឌិត* Martin Polkinghorne *ជួយឧបត្ថម្ភថវិកាកសាងដំបូលថ្មីប្រក់ក្បឿងក្នុងគោលបំណងអភិរក្សប្រាសាទ ទប់ស្កាត់ទឹកភ្លៀងហូរចូលប្រាសាទ ក៏ដូចជាផ្តល់លក្ខណៈងាយស្រួលដល់ការចូលគោរពបូជារបស់ប្រជាពលរដ្ឋផងដែរ។*

*អាជ្ញាធរមូលដ្ឋានផ្តល់ការគាំទ្រពល់គម្រោងស្រាវជ្រាវរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលហសការណ៍ជាមួយស្ថាប័នជាតិនិងអន្តរជាតិផ្សេងៗទៀត។ អាជ្ញាធរឃុំបានចូលរួមចុះសិក្សាស្រាវជ្រាវដល់ទីតាំងស្ថានីយ និងចង្អុលបង្ហាញអំពីប្រវត្តិទីតាំងស្ថានីយ មានដូចជាប្រវត្តិពាក់ព័ន្ធផ្សេងៗ។*

*លោកណៃសុកាជាអនុប្រធាននាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលបានដឹកនាំមន្ត្រីជំនាញចុះកំណត់ដែនការពារប្រាសាទនិងទីទួលបុរាណ បង្ហាញថា «ជាក់ស្តែង អាជ្ញាធរឃុំពេញចិត្ត រាប់តាំងពីលោកមេឃុំក៏គាត់ចូលរួមដែរ។ យើងបង្ហាញដល់អាជ្ញាធរថាមានស្លាកស្នាមមនុស្សរស់នៅមានសំណង់ប្រាសាទគឺជាកស្តុតាងវប្បធម៌ដែលត្រូវការពារ។ យើងបានពន្យល់ប្រាប់គាត់ គាត់មានការចាប់អារម្មណ៍ គាត់ចូលរួមសហការយ៉ាងជិតស្និទ្ធជាមួយយើង»[3]។*

---

[3] *សម្ភាសលោក ណៃ សុកា ជាអនុប្រធាននាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣។*




រូបលេខ២២ : មន្ត្រីជំនាញក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងសមាជិកអាជ្ញាធរដែនដីឃុំបារាយណ៍ ក្នុងដំណើរការកំណត់ដែនការស្ថានីយបុរាណក្នុងឃុំបារាយណ៍ នៅឆ្នាំ២០២៣



រូបលេខ២៣:លោកហ៊ាងមេសានិងលោកឈុនស្រ៊ុន ចុះកំណត់ទីតាំងការពារទីទួលបុរាណ នៅឆ្នាំ២០២៣

## ៥. លទ្ធផល

ដោយមានកិច្ចសហការណ៍ល្អ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានសម្រេចជោគជ័យក្នុងការចុះបញ្ជីស្ថានីយចំនួន៥៣ ក្នុងបញ្ជីបេតិកភណ្ឌជាតិ ដោយចេញជាប្លង់រឹង បង្ហាញទំហំដីនៃស្ថានីយប្រាសលាស់ ដែលចេញជាផ្លូវការដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
អគ្គនាយកដ្ឋានបេតិកភណ្ឌ
នាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា

បញ្ជីស្ថានីយបុរាណនៅក្នុងឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម

| ល.រ | ឈ្មោះ | ទីតាំង | ប្រភេទស្ថានីយ | WGS 1984 UTM Zone 48N | |
|---|---|---|---|---|---|
| | | | | X | Y |
| 1 | ទួលកក្តី | ភូមិកំផ្លាក់ | ទួលមនុស្សរស់នៅ | 521322 | 1308894 |
| 2 | ទួលត្រពាំងឫស្សី | ភូមិកំផ្លាក់ | ទួលមនុស្សរស់នៅ | 521049 | 1308815 |
| 3 | ទួលគុហ៍សាន | ភូមិកំផ្លាក់ | ទួលមនុស្សរស់នៅ | 520967 | 1308939 |
| 4 | ទួលអំពិលបាត | ភូមិកំផ្លាក់ | ទួលមនុស្សរស់នៅ | 521008 | 1309186 |
| 5 | ទួលគុកហ៊ី | ភូមិកំផ្លាក់ | ទួលមនុស្សរស់នៅ | 521185 | 1309345 |
| 6 | ទួលបុស្សពារ | ភូមិកំផ្លាក់ | ទួលមនុស្សរស់នៅ | 520628 | 1309968 |
| 7 | ទួលពាក់ខ្នាយ | ភូមិកំផ្លាក់ | ទួលគ្រឹះប្រាសាទ | 521291 | 1309879 |
| 8 | ទួលផ្នូរខ្មោច | ភូមិកំផ្លាក់ | ទួលមនុស្សរស់នៅ | 521416 | 1309644 |
| 9 | ទួលតាផុង | ភូមិកំផ្លាក់ | ទួលមនុស្សរស់នៅ | 521512 | 1309762 |
| 10 | ប្រាសាទព្រះធាតុ( ទួលបាសាន ) | ភូមិស្វាអំពិល | ប្រាសាទមានរូបរាង | 521559 | 1309055 |
| 11 | បារាយណ៍ | ភូមិស្វាអំពិល | សំណង់បារាយណ៍ | 521861 | 1309136 |
| 12 | ទួលតាព្រះ | ភូមិស្វាអំពិល | ទួលគ្រឹះប្រាសាទ | 522417 | 1309028 |
| 13 | ទួលតាមោគ | ភូមិស្វាអំពិល | ទួលមនុស្សរស់នៅ | 522164 | 1309020 |
| 14 | ទួលផ្កាថ្កឹម( ចំការតាគឹម ឬតាកាតាគឹម ) | ភូមិស្វាអំពិល | ទួលមនុស្សរស់នៅ | 522494 | 1308893 |
| 15 | ទួលចន្លក់ចាស់ | ភូមិស្វាអំពិល | ទួលមនុស្សរស់នៅ | 522499 | 1308766 |
| 16 | ទួលហ៊ុនឡេ | ភូមិស្វាអំពិល | ទួលមនុស្សរស់នៅ | 522313 | 1308677 |
| 17 | ទួលច្រលឹម | ភូមិស្វាអំពិល | ទួលមនុស្សរស់នៅ | 522082 | 1308787 |
| 18 | ទួលស្រែយូស | ភូមិស្វាអំពិល | ទួលមនុស្សរស់នៅ | 521793 | 1308850 |
| 19 | ទួលអាស៊ុម | ភូមិស្វាអំពិល | ទួលមនុស្សរស់នៅ | 521533 | 1308887 |
| 20 | ទួលរចេក | ភូមិស្វាអំពិល | ទួលមនុស្សរស់នៅ | 521705 | 1309199 |
| 21 | ទួលទន្លេអ៊ី( ទួលចេក ) | ភូមិស្វាអំពិល | ទួលមនុស្សរស់នៅ | 521883 | 1309201 |
| 22 | ទួលសុខស | ភូមិស្វាអំពិល | ទួលមនុស្សរស់នៅ | 521842 | 1309325 |
| 23 | ទួលខ្នារ | ភូមិស្វាអំពិល | ទួលមនុស្សរស់នៅ | 521973 | 1309358 |
| 24 | ទួលទន្លេអ៊ីប្រុស( តាតេង ) | ភូមិស្វាអំពិល | ទួលមនុស្សរស់នៅ | 521791 | 1309042 |
| 25 | ទួលតាចែម | ភូមិស្វាអំពិល | ទួលមនុស្សរស់នៅ | 521758 | 1308980 |
| 26 | ទួលតាភោង | ភូមិស្វាអំពិល | ទួលមនុស្សរស់នៅ | 521702 | 1309005 |
| 27 | ទួលភូមិបាក់ | ភូមិស្វាអំពិល | ទួលមនុស្សរស់នៅ | 521571 | 1309317 |
| 28 | ទួលតាសាំ | ភូមិស្វាអំពិល | ទួលមនុស្សរស់នៅ | 521854 | 1309825 |
| 29 | ទួលតាគង់ ឬទួលគុយក្ស | ភូមិស្វាបឹងវែង | ទួលអ្នកតា | 525612 | 1308000 |
| 30 | ទួលចានៀង | ភូមិស្វាបឹងវែង | ទួលអ្នកតា | 523969 | 1313217 |
| 31 | ទួលតាយូ | ភូមិស្វាបឹងវែង | ទួលអ្នកតា | 524411 | 1311828 |
| 32 | ទួលចេតិយ | ភូមិស្វាបឹងវែង | ទួលអ្នកតា និងឡបុរាណ | 524768 | 1312878 |
| 33 | ទួលកាន់ស្នេហ៍ | ភូមិស្វាបឹងវែង | ទួលមនុស្សរស់នៅ | 525713 | 1308428 |
| 34 | ទួលពោង | ភូមិស្វាបឹងវែង | ទួលមនុស្សរស់នៅ | 525540 | 1308801 |
| 35 | ទួលឡោក | ភូមិស្វាបឹងវែង | ទួលមនុស្សរស់នៅ | 525516 | 1309101 |
| 36 | ទួលកណ្តាល | ភូមិស្វាបឹងវែង | ទួលមនុស្សរស់នៅ | 525824 | 1309290 |
| 37 | ទួលវិហារ និងទួលស្លាយខ្ពស់ | ភូមិស្វាបឹងវែង | ទួលមនុស្សរស់នៅ | 526276 | 1308578 |
| 38 | ទួលតំលាវ | ភូមិស្វាបឹងវែង | ទួលមនុស្សរស់នៅ | 523350 | 1312217 |
| 39 | ទួលសំពេងជើង | ភូមិស្វាបឹងវែង | ទួលមនុស្សរស់នៅ | 524112 | 1312357 |
| 40 | ទួលតាក់ | ភូមិស្វាបឹងវែង | ទួលមនុស្សរស់នៅ | 524238 | 1312047 |
| 41 | ទួលសង្កែ | ភូមិស្វាបឹងវែង | ទួលមនុស្សរស់នៅ | 524356 | 1312098 |
| 42 | ទួលគុំបៅ | ភូមិស្វាបឹងវែង | ទួលមនុស្សរស់នៅ | 523805 | 1311763 |
| 43 | ទួលសំពេងត្បូង | ភូមិស្វាបឹងវែង | ទួលមនុស្សរស់នៅ | 524109 | 1311626 |
| 44 | ទួលកាក់ប | ភូមិស្វាបឹងវែង | ទួលមនុស្សរស់នៅ | 523998 | 1311337 |
| 45 | ទួលប្រាសាទត្បូង | ភូមិបន្ទាយ | ទួលគ្រឹះប្រាសាទ | 521378 | 1310295 |
| 46 | ទួលប្រាសាទជើង | ភូមិបន្ទាយ | ទួលគ្រឹះប្រាសាទ | 521372 | 1310375 |
| 47 | ទួលចាបពួក | ភូមិបន្ទាយ | ទួលអ្នកតា | 521506 | 1310494 |
| 48 | ទួលអ្នកតាតាណាល | ភូមិបន្ទាយ | ទួលគ្រឹះ | 523057 | 1310535 |
| 49 | ទួលការនោគ | ភូមិបន្ទាយ | ទួលមនុស្សរស់នៅ | 523599 | 1310856 |
| 50 | ទួលយាយសូត្រ | ភូមិបន្ទាយ | ទួលមនុស្សរស់នៅ | 523529 | 1310706 |
| 51 | ទួលរកា | ភូមិបន្ទាយ | ទួលមនុស្សរស់នៅ | 523461 | 1310510 |
| 52 | ទួលគោកឆ្មោត | ភូមិបន្ទាយ | ទួលមនុស្សរស់នៅ | 522672 | 1310428 |
| 53 | ទួលថ្វាន់ | ភូមិបន្ទាយ | ទួលមនុស្សរស់នៅ | 523227 | 1310444 |

សរុបមានចំនួន53ស្ថានីយបុរាណ៖
ប្រាសាទមានរូបរាងចំនួន 01 , សំណង់បារាយណ៍ចំនួន 01 , ទួលគ្រឹះ ឬគ្រឹះប្រាសាទចំនួន 05 , ទួលអ្នកតា និងឡបុរាណ ចំនួន 01 , ទួលអ្នកតាចំនួន 04 , ទួលមនុស្សរស់នៅចំនួន 41។

ថ្ងៃ......................ខែ.............ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី.........ខែ..............ឆ្នាំ២០២៣
**អ្នកធ្វើបញ្ជី**

**ហ៊ាង មេសា**

រូបលេខ២៤ : តារាងបញ្ជីរាយនាមប្រាសាទនិងទួលបុរាណដែលបានចុះបញ្ជីបេតិកភណ្ឌ (ប្រភព : លោក ហ៊ាង មេសា)

ឯកឧត្តម ប្រាក់ សុណ្ណារ៉ា រដ្ឋលេខាធិការនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈលើកឡើងអំពីគម្រោងស្រាវជ្រាវនៅឃុំបាពយណ៌ដែលមិនត្រឹមធ្វើកិច្ចការស្រាវជ្រាវ ចុះបញ្ជីបេតិកណ្ឌជាតិ ថែមទាំងបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ «ថ្នាក់ដឹកនាំជាពិសេសលោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានកំណត់ទិសដៅផ្សព្វផ្សាយឱ្យបានច្រើន ឱ្យបានជ្រួតជ្រាបដល់ប្រជាពលរដ្ឋ ដូចជាការផលិតជាវីដេអូឯកសារបង្ហាញពីលទ្ធផលស្រាវជ្រាវ។» ឯកឧត្តម ប្រាក់ សុណ្ណារ៉ា បានបន្តទៀតថា «គោលនយោបាយរបស់រាជរដ្ឋាភិបាល ដោយឡែកក្រសួងវប្បធម៌ មានគោលនយោបាយស្វែងរកដៃគូសហការ។ ដៃគូទាំងជាតិ និង អន្តរជាតិក្នុងការសិក្សាស្រាវជ្រាវ ស្វែងរកដៃគូទាំងមូលនិធិដើម្បីធ្វើយ៉ាងណា ចូលរួមគ្នាសហការស្រាវជ្រាវចាប់ពីចំណុចចាប់ផ្តើម ទៅដល់ចុងក្រោយបង្អស់ បានទទួលជោគជ័យ។ នេះគឺជាឧទាហរណ៍មួយ ដែលកិច្ចសហការណ៍រវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ជាមួយនឹងស្ថាបនជាតិរាជបណ្ឌិត្យសភា ជាមួយនឹងសាកលវិទ្យាល័យមកពីក្រៅប្រទេស គឺសាកលវិទ្យាល័យហ្វីនឌ័រ[4]។»



ឯកឧត្តម ប្រាក់ សុណ្ណារ៉ា រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងឱកាសចុះពិនិត្យសកម្មភាពស្រាវជ្រាវ នៅឃុំបាពយណ៌ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥

**-ពង្រឹងការយល់ដឹងសហគមន៍**:សហគមន៍មូលដ្ឋានកាន់យល់ដឹងអំពីតម្លៃនៃការរក្សាបេតិកភណ្ឌក្នុងតំបន់របស់ខ្លួន។

លោក ឈុន ស្រ៊ុន មេឃុំបាពយណ៌ ដែលបានចូលរួមក្នុងកិច្ចសហប្រតិបត្តិការនេះ បានលើកឡើងថា «ក្នុងនាមអាជ្ញាធរឃុំ យើងខ្ញុំមានការតព្វកិច្ចចូលរួមសហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈដើម្បីកំណត់ទីទួល

[4] សម្ភាសឯកឧត្តម ប្រាក់ សុណ្ណារ៉ា រដ្ឋលេខាធិការនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥។

បុរាណទីទួលបុរាណរបស់យើង។ យើងនឹងផ្សព្វផ្សាយ ជម្រាបជូនដល់ប្រជាពលរដ្ឋ ក្នុងភូមិទាំង៤ មានភូមិស្បាអំពិល ភូមិកំផ្លាក់ ភូមិបន្ទាយ និងភូមិស្បាបឹងវែង ដើម្បីឱ្យគាត់ចូលរួមសហការ។ ដីទាំងអស់នេះ គឺជាទីទួល ដែលយើងបានជាកំណត់ជាដីទួលបុរាណ គឺពួកគាត់មិនអាចធ្វើជាកម្មសិទ្ធស្របច្បាប់បានទេ ហើយដែលនឹងគ្រប់គ្រងដោយរដ្ឋបាលឃុំ ក៏ដូចក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ»[5]។



**-បណ្តុះបណ្តាលនិស្សិតនិងអ្នកជំនាញបុរាណវត្ថុវិទ្យាកម្ពុជា**

គម្រោងស្រាវជ្រាវក៏បានបញ្ចូលកម្មវិធីបណ្តុះបណ្តាលនិស្សិត និងពង្រឹងចំណេះជំនាញដល់មន្ត្រីជំនាញនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដែរ។

លោកបណ្ឌិត Martin Polkinghorne គឺជាអ្នកស្រាវជ្រាវជនជាតិអូស្ត្រាលី ដែលមានបទពិសោធន៍ស្រាវជ្រាវក្នុងប្រទេសកម្ពុជា តាំងពីឆ្នាំ២០១១ រហូតដល់បច្ចុប្បន្ន និងបានចូលរួមបណ្តុះបណ្តាលជំនាញដល់និស្សិតក៏ដូចជាមន្ត្រីជំនាញខ្មែរជាច្រើនទៀត។



**-បង្កើតគំរូសម្រាប់ឃុំផ្សេងទៀត**

ជាគំរូមួយដល់ឃុំ ឬ ស្រុកផ្សេងទៀតក្នុងប្រទេសកម្ពុជា យកជាគំរូបសម្រាប់កិច្ចការអភិរក្សស្ថានីយបុរាណ។

## ៦. សេចក្តីសន្និដ្ឋាន

គម្រោងស្រាវជ្រាវបុរាណវត្ថុវិទ្យានៅឃុំបាពយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម បានទទួលលទ្ធផលទាំងវិស័យវិទ្យាសាស្ត្រ និងការពង្រីកកិច្ចសហការរួមគ្នា ទាំងថ្នាក់

[5] សម្ភាសលោក ឈុន ស្រ៊ុន មេឃុំបាពយណ៍ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣។

ជាតិនិងអន្តរជាតិ។ សាកលវិទ្យាល័យហ្វ៊ីនឌ័រ ប្រទេសអូស្ត្រាលី ជាភាគីផ្តួចផ្តើមគំនិត មានទាំងថវិកា ផ្តល់ទាំងជំនួយបច្ចេកទេស សហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រាជបណ្ឌិត្យសភាកម្ពុជា រួមជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋានឃុំបាភយណ៍ ចូលរួមសិក្សាស្រាវជ្រាវចាប់ពីចំណុចចាប់ផ្តើម រហូតដល់ចំណុចអភិរក្សប្រាសាទ ទីទួលបុរាណដោយជោគជ័យ។ នេះគឺជាគំរូមួយនៃការងារអភិរក្សស្ថានីយបុរាណ ក៏ដូចជាសម្បត្តិបេតិកភណ្ឌជាតិកម្ពុជា ប្រកបដោយចីរភាព។

លោក ឈុន ស្រ៊ុន បង្ហាញពីភាពជោគជ័យរបស់សហគមន៍ឃុំបាភយណ៍ក្នុងការងារអភិរក្សប្រាសាទ និងទីទួលបុរាណក្នុងឃុំបាភយណ៍ថា «ការរំពឹងទុករបស់យើងខ្ញុំក្នុងនាមប្រធានក្រុមប្រឹក្សា ខ្ញុំគិតថាទួលនេះគឺបានឋិតថេរយូរអង្វែង ដោយសារប្រជាពលរដ្ឋរបស់យើងខ្ញុំនៅក្នុងភូមិទាំង៤មានការចូលរួមទាំងអស់គ្នា។ គិតថាថ្ងៃក្រោយ ទីទួលបុរាណរបស់យើងនឹងប្រើប្រាស់សម្រាប់ប្រទេសជាតិយើង»[6]។

## សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណដល់៖

-សាកលវិទ្យាល័យ Flinders ប្រទេសអូស្ត្រាលី ដែលបានផ្តួចផ្តើមគំនិតសិក្សាស្រាវជ្រាវ បណ្តុះបណ្តាល និងផ្តល់ថវិកា

-ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលបានចុះបញ្ជីស្ថានីយជាផ្លូវការ

-រាជបណ្ឌិត្យសភាកម្ពុជា ដែលបានចូលរួមកិច្ចការស្រាវជ្រាវ និង អភិរក្សតាំងពីឆ្នាំ ២០១៩ ដល់ឆ្នាំ២០២៥

-មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ចាម បានចូលរួមស្រាវជ្រាវ និង

-អាជ្ញាធរ ព្រមទាំងសហគមន៍ឃុំបាភយណ៍ ដែលបានចូលរួមសហការយ៉ាងសកម្ម។

[6] សម្ភាសលោក ឈុន ស្រ៊ុន មេឃុំបាភយណ៍ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣។

**កិច្ចសម្ភាសន៍៖**

*១-ឯកឧត្តម ប្រាក់ សុណ្ណារ៉ា រដ្ឋលេខាធិការនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥។*

*២-លោក ណៃ សុភា អនុប្រធាននាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣។*

*៣-លោក ឈុន ស្រ៊ុន មេឃុំបាពាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ ២០២៣។*

*៤-លោក គង់ សុមុនី គឺជាជំទប់ទី១ ឃុំបាពាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម សម្ភាសនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៣។*

*៥-លោក លឹម ព្រែក ឆ្មាំប្រាសាទព្រះធាតុបាពាយណ៍ រស់នៅក្នុងភូមិស្យាអំពិល ឃុំបាពាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម សម្ភាសនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៣។*